*Insight: Cambodia Journal of Basic and Applied Research,* Volume 2 Number 2 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

# ខ្នាតរង្វាស់តម្លាភាព គណនេយ្យភាព និងការចូលរួមពីភាគីពាក់ព័ន្ធស្តីពីការប្រើប្រាស់ថវិកាកម្មវិធីនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើទ្រឹស្តី "អភិបាលកិច្ចល្អ"

**ប៉ិញ សឿន** *

**បេក្ខជនបណ្ឌិត សាកលវិទ្យាល័យវេស្ទើន** ( Western University ) **សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា**

*Corresponding Author: PENH Soeun (penhsoeun2050@gmail.com)

**To cite this article:** Penh, S. (2020). Transparency, Accountability and stakeholder Measurement Engagement on Budget Utilizaton Programs at Public Higher Education Institution of the Kingdom of Cambodia Base on Government Theory. *Cambodia Journal of Basic and Applied Research (CJBAR), 2(2)*, 67–92.

## សង្ខិត្តន័យ

នៅឆ្នាំ២០០៤ ផែនការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលមានបួនដំណាក់កាល ក្នុងនោះ មានទាំងការដាក់ចេញនូវគោលនយោបាយហិរញ្ញប្បទានរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាសម្រាប់ឧត្តមសិក្សាសាធារណៈ ក្នុងគោលដៅលើកកម្ពស់អនុកម្មវិធីឧត្តមសិក្សាទាំង១២។ ការសិក្សាស្រាវជ្រាវនេះផ្តោតសំខាន់លើខ្នាតរង្វាស់ទាំងបី នៃការអនុវត្តថវិកាកម្មវិធីនៅគ្រឹះស្ថានសិក្សាសាធារណៈ ដែលរួមមាន៖ (១) ការចូលរួមពីភាគីពាក់ព័ន្ធ (២) តម្លាភាព និង (៣) គណនេយ្យភាព។ ការស្រាវជ្រាវនេះបង្ហាញថា តម្លាភាពនិងគណនេយ្យភាពនៃការអនុវត្តថវិកាដែលបាននឹងកំពុងអនុវត្តនៅមានកម្រិតនៅឡើយ ព្រោះគ្រប់ការអនុវត្តថវិកាមានភាពឆ្លើយតបទៅនឹងផែនការសកម្មភាពតិច និងមិនចំគោលដៅរបស់ការិយាល័យ មហាវិទ្យាល័យ និងដេប៉ាតឺម៉ង់។ ម្យ៉ាងទៀតរាល់ព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យមិនបានផ្សព្វផ្សាយឱ្យទូលំទូលាយនៅក្នុងអង្គភាពថវិកានៅឡើយ។ ការស្រាវជ្រាវបង្ហាញផង

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ដែរថា ការចូលរួមពីភាគីពាក់ព័ន្ធក៏នៅមានកម្រិតទាបដែរ ព្រោះ ជាទូទៅ រាល់ការសម្រេចចិត្តផ្នែកថវិកាកម្មវិធីត្រូវបានធ្វើឡើងត្រឹមគណៈគ្រប់គ្រងជាន់ខ្ពស់ និងផ្នែករដ្ឋទេយ្យតែប៉ុណ្ណោះ ចំណែកភាគីពាក់ព័ន្ធដទៃទៀតត្រូវចាំទទួលយកកញ្ចប់ថវិកាទៅអនុវត្តផែនការសកម្មភាពតែម្តង។

**Abstract**
In 2004, the Public Financing Reform Plan of the Royal Government of Cambodia was released. It comprised four phases, including the launch of the financing policy for public universities developed by the Ministry of Education, Youth and Sport. This study focuses on the three criteria used for implementing program budgets in public higher education institutions: transparency, accountability, and stakeholder engagement, which are implemented through twelve sub-programs. It demonstrates that the transparency and accountability of budgets are still limited, evidenced by the lack of responsiveness to budget allocations outlined in the action plans of relevant departments within higher education institutions. While financial information is widely disseminated, the participation of stakeholders in research activities is constrained as decisions about program budgets tend to be made only by the senior management, while other stakeholders are required to accept allocated budgets for implementing their action plans.

**Keywords:** transparency, accountability, stakeholder engagement, public universities

## សេចក្តីផ្តើម

ថវិកាដែលរាជរដ្ឋាភិបាលចំណាយលើវិស័យឧត្តមសិក្សា ប្រែប្រួលទៅតាមសម័យកាល និងរបបគ្រប់គ្រងរដ្ឋ។ យើងពុំឃើញមានរូបរាងពិតប្រាកដនៅសម័យមុនអង្គរ និងសម័យអង្គរទេ។ សម័យក្រោយអង្គរនិងសម័យអាណានិគមនិយមបារាំងក៏ពុំមានតួលេខច្បាស់លាស់ដែរ។ ដោយឡែកនៅសម័យសង្គមរាស្ត្រនិយម ពីឆ្នាំ១៩៥៣-១៩៦៤ រាជរដ្ឋាភិបាលបានចំណាយថវិកាលើវិស័យអប់រំខ្ពស់ជាងវិស័យការពារជាតិ គឺពី ១៥.៥៤% ដល់ ២២.៥៦% (Lee C & Gildas, 26 (1), 1997)។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ឆ្នាំ១៩៥៣ ក្រោយកម្ពុជាទទួលបានឯករាជ្យបរិបូរណ៍ពីអាណានិគមនិយមបារាំង ពោលគឺនៅសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជដឹកនាំរបស់សម្តេចព្រះនរោត្តមសីហនុ រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានចំណាយថវិកាជាតិប្រមាណជា ២០% នៃថវិកាជាតិសរុប ដើម្បីពង្រឹងប្រព័ន្ធអប់រំនៅឧត្តមសិក្សាមានការប្រកួតប្រជែងទូទាំងអាស៊ីអាគ្នេយ៍ និងដើម្បីលុបបំបាត់ផ្នត់គំនិតអាណានិគមបារាំង និងបណ្តុះផ្នត់គំនិតជាតិនិយម (Clayton, 34 (4) 2005)។

នៅចន្លោះឆ្នាំ១៩៧០ និង ១៩៩៣ កម្ពុជារងគ្រោះដោយសារសង្គ្រាមរ៉ាំរ៉ៃ។ ប៉ុន្តែ ចាប់ពីឆ្នាំ២០០០ ដល់ ២០១០ រាជរដ្ឋាភិបាលបានវិនិយោគថវិកាលើវិស័យអប់រំផ្នែកឧត្តមសិក្សាគួរឲ្យកត់សម្គាល់។ ជាក់ស្តែងក្នុងឆ្នាំ២០១០ ដើម្បីពង្រឹងអនុវិស័យឧត្តមសិក្សានៅប្រទេសកម្ពុជា រាជរដ្ឋាភិបាលបាននិយោគទៅលើផ្នែកឧត្តមសិក្សាក្រោមគម្រោង (HEQCIP) គិតជាទឹកប្រាក់សរុបប្រមាណ ២៣លានដុល្លារ សម្រាប់រយៈពេល៥ឆ្នាំ។ គម្រោងវិនិយោគនេះគឺដើម្បីពង្រឹងសមាសភាគគន្លឹះចំនួន ៤[1] ធំៗនៅឧត្តមសិក្សា (Rappleye and Un, 2018)។ ឆ្នាំ២០១០ ដដែលនេះ ដើម្បីពង្រឹងសមត្ថភាពការអប់រំនៅគ្រឹះស្ថានឧត្តមសិក្សា ក្រសួងអប់រំបានចំណាយថវិកាមួយភាគបីនៃថវិកាសរុបរបស់ខ្លួន (Kuy, 2013)។ ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានផ្តល់ថវិកាទាបសម្រាប់អនុវិស័យឧត្តមសិក្សា ដោយទទួលបានត្រឹមតែ ០,១% នៃ GDP ឬ ៤,១% នៃថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា (Sen, 2017)។

ចំពោះហិរញ្ញប្បទានមាន ៤% នៃថវិកាប្រចាំឆ្នាំរបស់ខ្លួនសម្រាប់អនុវិស័យឧត្តមសិក្សា។ ប៉ុន្តែ ចាប់ពីឆ្នាំ ២០១៤ រហូតដល់ឆ្នាំ ២០១៨ ថវិកាចំណាយផ្នែកឧត្តមសិក្សាមានការកើនឡើងជាលំដាប់ (UNESCO, 2015)។ ជាក់ស្តែង គេឃើញការចំណាយថវិកាមកលើផ្នែកឧត្តមសិក្សាមានការកើនឡើងគឺ ២១០,០៥ ពាន់លានរៀលក្នុងឆ្នាំ២០១៤, ២៤៦,៥៦០ ពាន់លានរៀលក្នុងឆ្នាំ២០១៥, ២៧២,៤៦៩ ពាន់លានរៀលក្នុងឆ្នាំ២០១៦, ៣១៣,៩៩៧ ពាន់លានរៀលក្នុងឆ្នាំ២០១៧ និង ៣៩២,៦៣៦ ពាន់លានរៀលក្នុងឆ្នាំ២០១៨ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៤-២០១៨)។ ក្របខណ្ឌហិរញ្ញប្បទានវិស័យអប់រំមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងថវិការាជរដ្ឋាភិបាល។ ភាគច្រើននៃកម្មវិធីអាទិភាពត្រូវបានអនុវត្តដោយប្រើប្រាស់ថវិកាចន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាពេលបច្ចុប្បន្ន ហិរញ្ញប្បទាន

[1] សមាសភាពគន្លឹះទាំង ៤ របស់គម្រោង HEQCIP នោះគឺ (១) ពង្រឹងសមត្ថភាពនៃការអប់រំឧត្តមសិក្សា, (២) ជំនួយអភិវឌ្ឍន៍និងផ្តល់ការអភិវឌ្ឍប្រកបដោយការប្រកួតប្រជែង, (៣) ផ្តល់អាហារូបករណ៍ដល់សិស្ស-និស្សិតដែលងាយរងគ្រោះ និង (៤) ការត្រួតពិនិត្យគម្រោងនិងការវាយតម្លៃ។

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 Number 2 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ខាងក្រៅក្នុងវិស័យអប់រំត្រូវបានផ្តល់តាមរយៈថវិកាគាំទ្រ គម្រោងវិនិយោគមូលធន គម្រោងកសាងសមត្ថភាព និងកម្មវិធីអាទិភាពចរន្តមួយចំនួនទៀត។ ចំណាយសាធារណៈសរុបលើវិស័យអប់រំគឺជាផលបូកចំណាយនៃថវិការដ្ឋ កម្មវិធីជំនួយ និងកម្មវិធីគាំទ្រ។ គោលដៅនៃក្រសួងអប់រំ យុវជន និងកីឡា គឺបង្កើតនូវសេវាអប់រំប្រកបដោយសមភាពក្នុងការទទួលបាន និងមានគុណភាពខ្ពស់។

ចក្ខុវិស័យក្រសួងអប់រំ យុវជន និងកីឡា គឺការស្វែងយល់ពីតម្រូវការចាំបាច់នៃប្រព័ន្ធបណ្តុះបណ្តាលនិងអប់រំ ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ច បង្កើនលទ្ធភាពបានការងារ និងបង្កើនឱកាសរកប្រាក់ចំណូល។ ជាងនេះទៅទៀត ចំណាយលើប្រាក់បៀវត្សមានចំនួន ១,៦២៧ ពាន់លានរៀល ដែលស្មើនឹង ១៣,៦៧% នៃចំណាយចរន្ត (ហង់, ២០១៦)។ ការដាក់ចេញនូវគោលនយោបាយហិរញ្ញប្បទានរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាសម្រាប់ឧត្តមសិក្សាសាធារណៈក្នុងគោលដៅលើកកម្ពស់អនុកម្មវិធីឧត្តមសិក្សាចំនួន ១២[2] (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៤-២០១៨)។ ក្របខណ្ឌអភិបាលកិច្ចល្អ ការអនុវត្តវិស័យអប់រំឆ្នាំ២០៣០ នឹងតម្រូវឱ្យមានយន្តការថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលសម្រាប់អភិបាលកិច្ច គណនេយ្យភាព ការសម្របសម្រួល ការអង្កេតតាមដាននិងការពិនិត្យឡើងវិញ ការរាយការណ៍និងការវាយតម្លៃ(UNESCO, 2015)។

## អំពីអភិបាលកិច្ច តម្លាភាព គណនេយ្យភាព និងភាគីពាក់ព័ន្ធ

តាមការស្រាវជ្រាវនានា មានទស្សនៈជាច្រើនផ្សេងៗគ្នាអំពី "អភិបាលកិច្ច"។ ដំបូងឡើយ "អភិបាលកិច្ច" ត្រូវបានប្រើដើម្បីពណ៌នាពីតម្រូវការសម្រាប់កំណែទម្រង់ស្ថាប័ន និងវិស័យសាធារណៈ ឱ្យមានប្រសិទ្ធភាពនិងប្រសើរជាងមុននៅក្នុងប្រទេសអនុតំបន់សាហារ៉ាអាហ្វ្រិក។ តាមលោក Barber Conable (1986-1991) អតីតប្រធានធនាគារពិភពលោក "អភិបាលកិច្ច

[2] អនុកម្មវិធីអាទិភាពទាំង ១២ នៃការប្រើប្រាស់ថវិកាសម្រាប់ឧត្តមសិក្សាគឺ **អនុកម្មវិធីទី១** ការលើកកម្ពស់គុណភាព និងការឆ្លើយតបនៃការអប់រំឧត្តមសិក្សា, **អនុកម្មវិធីទី២** ការពង្រឹងគុណភាព និងការឆ្លើយតបនៃការបណ្តុះបណ្តាលកម្រិតឧត្តម និងក្រោយឧត្តមប្រកបដោយប្រសិទ្ធភាព, **អនុកម្មវិធីទី៣** ការពង្រឹងគុណភាព ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ, **អនុកម្មវិធីទី៤** លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ, **អនុកម្មវិធីទី៥** ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ, **អនុកម្មវិធីទី៦** ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ, **អនុកម្មវិធីទី៧** ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ, **អនុកម្មវិធីទី៨** ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនិងស្រាវជ្រាវ, **អនុកម្មវិធីទី៩** ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវ, **អនុកម្មវិធីទី១០** ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា, **អនុកម្មវិធីទី១១** ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ការស្រាវជ្រាវ និងសេវាសហគមន៍, **អនុកម្មវិធីទី១២** ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ល្អ” គឺសំដៅលើសេវាសាធារណៈដែលមានប្រសិទ្ធភាព ប្រព័ន្ធតុលាការដែលអាចទុកចិត្តបាន និងរដ្ឋបាលដែលមានគណនេយ្យភាពចំពោះសេវាសាធារណៈនោះ។

ឆ្នាំ១៩៩២ ធនាគារពិភពលោកប្រើជា “អភិបាលកិច្ចនិងការអភិវឌ្ឍ” ដែលមានន័យថា លក្ខណៈនៅក្នុងអំណាចដែលត្រូវបានអនុវត្តក្នុងការគ្រប់គ្រងស្ថាប័នមួយ និងការបែងចែកធនធានសេដ្ឋកិច្ចនិងសង្គមសម្រាប់ការអភិវឌ្ឍ។ ឆ្នាំ១៩៩៤ ធនាគារពិភពលោកបានបញ្ជាក់បន្ថែមថា “អភិបាលកិច្ច” ត្រូវបានបង្ហាញដោយការព្យាករណ៍បើកចំហ និងការបង្កើតគោលនយោបាយបំភ្លឺ (នោះគឺតម្លាភាព)។ ឆ្នាំ១៩៩៨ កម្មវិធីអភិបាលកិច្ចអាស៊ីប្រែពីវិបត្តទៅជាឱកាស។ ការបោះពុម្ពផ្សាយប្រចាំឆ្នាំរបស់ធនាគារពិភពលោកពេលនោះ “អភិបាលកិច្ច” មានសមាសធាតុធំៗបួនគឺ៖ (១) គណនេយ្យភាព (២) តម្លាភាព (៣) អាចប៉ាន់ប្រមាណបាន និង (៤) ការចូលរួមពីភាគីពាក់ព័ន្ធ (Tripathi, 2017)។ ម្យ៉ាងទៀត “អភិបាលកិច្ច” គឺជាការប្រើប្រាស់អំណាចនយោបាយ។ កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ “អភិបាលកិច្ច” គឺការធ្វើលំហាត់នយោបាយសេដ្ឋកិច្ច និងអាជ្ញាធររដ្ឋបាលក្នុងការគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ (Tripathi, 2017)។

ឆ្នាំ២០១០ តាមធនាគារពិភពលោក “អភិបាលកិច្ច” មានសមាសភាពបួនដដែល តែមានការកែប្រែតិចតួចគឺ៖ (១) សេវាគ្រប់គ្រងសាធារណៈ (២) គណនេយ្យភាព (៣) នីតិរដ្ឋ និងការអភិវឌ្ឍ និង (៤) តម្លាភាពនិងប្រព័ន្ធព័ត៌មាន, (Maldonado, 2010)។ ម្យ៉ាងទៀត “អភិបាលកិច្ច” អាចមានសមាសភាគច្រើនជាងនេះគឺ៖ (១) ការចូលរួម (២) ភាពស៊ីសង្វាក់គ្នាក្នុងអង្គភាព (៣) គណនេយ្យភាព (៤) តម្លាភាព (៥) ទំនួលខុសត្រូវ (៦) ប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ (៧) សមធម៌និងបរិយាប័ន្ន[3] (៨) អនុវត្តតាមនីតិរដ្ឋ (Arulrajah, 2016)។ ដោយឡែក បញ្ញត្តិនៃអភិបាលកិច្ចល្អនៅប្រទេសអង់គ្លេសត្រូវបានវាស់ដោយឧបករណ៍ធំៗពីរគឺ៖ (១) តម្លាភាព និង (២) គណនេយ្យភាពបែបប្រជាធិបតេយ្យតាមរយៈការប្រើប្រាស់ថវិកាកម្មវិធី (PB) ក្នុងទីក្រុង និងរដ្ឋបាលក្រុង។ ឧបករណ៍ទាំងពីរនោះត្រូវបានប្រើដើម្បីវាស់ឱ្យដឹងថា៖ (១) តើថវិកាកម្មវិធីអាចធ្វើឱ្យប្រសើរឡើងនូវតម្លាភាព គណនេយ្យភាព

[3] បរិយាប័ន្ន ស្នើរប្រើបច្ចេកសព្ទនេះក្នុងន័យសងត្រឡប់ទៅនឹងបច្ចេកសព្ទភាសាអង់គ្លេសថា inclusive ដែលតាមវចនានុក្រមពីរភាសាអង់គ្លេស-ខ្មែរពន្យល់ថា “ដែលមាននៅក្នុង, ដែលរាប់បញ្ចូល, ដែលបំព្រួញ, ដែលយល់ច្បាស់, ...”។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

និងលទ្ធិប្រជាធិបតេយ្យក្នុងក្រុង និងរដ្ឋបាលក្រុងឬទេ? (២) តើថវិកាកម្មវិធីជាឧបករណ៍សម្របសម្រួលរវាងការគ្រប់គ្រង តម្លាភាព និងលទ្ធិប្រជាធិបតេយ្យក្នុងក្រុង និងរដ្ឋបាលក្រុងឬទេ? (Maria Isabel Brun-Martos et al. 2016)។

ចំណែកកម្មវិធីអភិវឌ្ឍធនធានមនុស្សសកល អភិបាលកិច្ចល្អមានសមាសភាគចំនួន១០ គឺ៖ (១) ការចូលរួម (២) គណនេយ្យភាព (៣) ការមិនរើសអើង (៤) សមភាព (៥) សហប្រតិបត្តិការ (៦) តម្លាភាព (ភាពជាម្ចាស់ ភាពត្រឹមត្រូវ) (៧) ប្រព័ន្ធបច្ចេកវិទ្យា (៨) ការផ្តល់ឱកាសដល់ផ្នែកសេវាសាធារណៈ (៩) ភាពស្របច្បាប់ (១០) រដ្ឋអធិបតេយ្យ/នីតិរដ្ឋ ដែលទាំងអស់នេះ រដ្ឋាភិបាលត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យមានអភិបាលកិច្ចធនធានមនុស្ស ឬអភិបាលកិច្ចសកល (Weiss, 2010)។

លើសពីនេះទៅទៀត "អភិបាលកិច្ច" ជាពាក្យចេញពីរដ្ឋាភិបាលតែម្តង គឺជាអ្នកគ្រប់គ្រង អ្នកបីបាច់រក្សា អ្នកថែរក្សា ការគ្រប់គ្រង ការបីបាច់ ការរក្សា។ ចំណែកពាក្យ "រដ្ឋាភិបាល" មានភាពស្និតស្នាលនិងបង្ហាញពីចរិតលក្ខណៈ ឬសកម្មភាពរបស់រដ្ឋាភិបាល (Choun, 1967)។ ម្យ៉ាងទៀត ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាក៏បានយកចិត្តទុកដាក់ចំពោះបញ្ញត្តិនេះផងដែរថា "អភិបាលកិច្ចល្អ" គឺជាបុរេលក្ខខណ្ឌសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌ក្នុងសង្គម (ក្រសួងមហាផ្ទៃ, ឆ្នាំ ២០១៣)។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បានធ្វើកំណែទម្រង់របបគ្រប់គ្រងរដ្ឋ ដោយយកអភិបាលកិច្ចជាស្នូល ពោលគឺ ឆ្នាំ២០០៤ "យុទ្ធសាស្ត្រចតុកោណ" ដំណាក់កាលទី១ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាសម្រាប់នីតិកាលទី៣នៃរដ្ឋសភា និងឆ្នាំ២០១៣ "យុទ្ធសាស្ត្រចតុកោណ" របស់រាជរដ្ឋាភិបាល ដំណាក់កាលទី៣ នីតិកាលទី៤នៃរដ្ឋសភាបានយក "អភិបាលកិច្ចល្អ" ជាធាតុស្នូលនិងជាបន្ទាត់នយោបាយក្នុងការគ្រប់គ្រង និងដឹកនាំរាជរដ្ឋាភិបាល។ ម្យ៉ាងទៀត យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ដំណាក់កាលទី៤ "អភិបាលកិច្ច" នៅតែជាចំណុចអាទិភាព។ ដើម្បីឱ្យកម្មវិធី អភិបាលកិច្ចល្អនេះអាចដំណើរការទៅបាន លុះត្រាតែមានការចូលរួមពីតួអង្គសំខាន់ៗគឺ៖ (១) ស្ថាប័នរដ្ឋ (ស្ថាប័ននយោបាយ និងរដ្ឋបាល) (២) វិស័យឯកជន និង (៣) សង្គមស៊ីវិល (ក្រសួងមហាផ្ទៃ, ឆ្នាំ២០១៣)។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនេះ អង្គភាពនីមួយៗចាំបាច់ត្រូវពង្រឹងការគ្រប់គ្រងធនធានមនុស្ស ដែលមានសមត្ថភាពឱ្យមានប្រសិទ្ធភាពនិងប្រកបដោយចីរភាព។ ធនធានមនុស្សប្រកបដោយសមត្ថភាពកំពុងដើរតួនាទីសំខាន់ក្នុងអង្គភាពនិរន្តរភាព ដោយមានការរួមចំណែកជាទូទៅ។ ការរីកចម្រើននៃអភិបាលកិច្ចល្អក៏មានសារៈសំខាន់ផងដែរសម្រាប់និរន្តរភាពនៃអង្គភាព។ ប្រសិនបើការគ្រប់គ្រងធនធានមនុស្សមានតួនាទីសំខាន់ចំពោះនិរន្តរភាពរបស់អង្គភាព ការស្វែងរកព័ត៌មានអង្គភាព និងការពិនិត្យឡើងវិញអំពីរបៀបដែលធនធានមនុស្សអាចរួមចំណែកដល់ការបង្កើតឱ្យមានអភិបាលកិច្ចល្អក្នុងអង្គភាពមួយប្រាកដជាអាចធ្វើទៅបាន។ គោលគំនិតនៃអភិបាលកិច្ចល្អបង្ហាញពីគោលគំនិត និងទំនាក់ទំនងរវាងអភិបាលកិច្ចល្អនិងធនធានមនុស្សនៅក្នុងវិជ្ជាជីវៈគ្រប់គ្រងអង្គភាពបច្ចុប្បន្ន។ ឆ្នាំ២០១៨ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា បន្តការកែទម្រង់អភិបាលកិច្ចដែលជាស្នូលក្នុងការធ្វើកំណែទម្រង់ ដោយបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ចល្អ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨)។

តាមការស្រាវជ្រាវ "តម្លាភាព" មានន័យថា ការសម្រេចចិត្តត្រូវបានអនុវត្តឱ្យឆ្លើយទៅនឹងការស្នើសុំក្នុងក្របខណ្ឌច្បាប់។ គោលការតម្លាភាពត្រូវផ្តល់នូវសិទ្ធទទួលបានព័ត៌មានដោយសេរីនិងយុត្តិធម៌ ទទួលបានការចូលរួមសម្រេចចិត្តដោយផ្ទាល់ ឬដោយប្រយោលក្នុងអង្គភាព។ គោលនយោបាយតម្លាភាពក្នុងការគ្រប់គ្រងគឺៈ (១) បង្ហាញពីភាពស្មោះត្រង់ចំពោះអង្គភាព គោលនយោបាយផ្លាស់ប្តូររបស់អង្គភាពសម្រាប់រយៈពេលវែង ធ្វើឱ្យគោលនយោបាយនិងលទ្ធផលមានភាពស៊ីសង្វាក់គ្នាសម្រាប់អង្គភាព និងគោលនយោបាយផ្តល់តម្លៃដល់នយោជិត (២) គោរពសិទ្ធនិងស្វ័យភាពរបស់អង្គភាព ផ្តល់សេរីភាពនៃការទទួលព័ត៌មានដល់គ្រប់ភាគីពាក់ព័ន្ធ ផ្តល់ការសម្រេចចិត្តដល់នយោជិតគ្រប់ទីកន្លែងដែលពួកគេនៅ មានភាពស៊ីសង្វាក់គ្នារវាងថ្នាក់លើនិងថ្នាក់ក្រោម (Arulrajah, 2016)។

តាមការស្ទង់មតិដោយពិនិត្យរកមើលតម្លាភាពតាមរយៈការប្រើប្រាស់ថវិការបស់ធនាគារពិភពលោកនៅក្នុងបណ្តាប្រទេសអឺរ៉ុបភាគខាងកើត យន្តការដែលគេបានប្រើដើម្បីពិនិត្យរកតម្លាភាពក្នុងការប្រើប្រាស់ថវិកានោះគឺៈ (១) ពិភាក្សាអំពីថវិកាដែលបានគ្រោងទុកជាមួយអង្គការសង្គមស៊ីវិល (២) រៀបចំវេទិកាថវិកាសាធារណៈ (៣) ផ្សព្វផ្សាយសេចក្តីព្រាងថវិកាមុនពេលក្រុមប្រឹក្សាក្រុងបានបោះឆ្នោតសម្រេច (៤) បង្កើតប្រព័ន្ធព័ត៌មានថវិកាក្នុងអង្គភាព/

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

តំបន់ (៥) បង្កើតវេទិកាសាធារណៈកញ្ចប់ថវិការបស់រដ្ឋាបាល និង (៦) បង្ហាញកញ្ចប់ថវិកាដែលបានអនុម័តធៀបនឹងឆ្នាំចាស់ (Kownley, 2006)។ តាមព្រឹត្តិបត្រចុះផ្សាយស្តីពីរដ្ឋាភិបាលបើកចំហ សមាសភាគដែលនាំឱ្យមានតម្លាភាពថវិកាមានបីធំៗគឺៈ (១) ការបង្កើតប្រព័ន្ធព័ត៌មាននិងចេញផ្សាយឱ្យទាន់ពេលវេលា (២) ប្រសិទ្ធភាពតាមផ្លូវច្បាប់ និង (៣) ប្រសិទ្ធភាពសង្គមស៊ីវិលតាមរយៈការផ្តល់សេវាសាធារណៈ (Wirtz and Birkmeyer, 2015)។

ដោយឡែក បញ្ញត្តិតម្លាភាព ទាំងប្រទេសកំពុងអភិវឌ្ឍ ទាំងប្រទេសអភិវឌ្ឍហើយ ចាំបាច់ត្រូវមានៈ (១) ការចូលរួម (២) ធនធាន (៣) ភាពជាអ្នកដឹកនាំ (៤) ការបណ្តុះបណ្តាល (៥) វប្បធម៌ការិយាធិបតេយ្យ និង (៦) រដ្ឋបាលសមត្ថភាព (Eccleston & Stubbs, 2016)។ តាមព្រឹត្តិប័ត្រ Popular Financial Reports as Fiscal Transparency Mechanisms របៀបធ្វើឱ្យមានតម្លាភាពក្នុងរបាយការណ៍ហិរញ្ញវត្ថុពន្ធដាដើម្បីបង្កើតអភិបាលកិច្ចល្អគឺៈ (១) ធ្វើបច្ចុប្បន្នភាពព័ត៌មាន (២) កំណត់ស្តង់ដារនិងពន្យល់ពីលំហូររបាយការណ៍ហិរញ្ញវត្ថុនោះ (៣) របាយការណ៍ហិរញ្ញត្រូវផ្តល់ឱ្យដល់អ្នកអានជាសាធារណៈ (៤) បច្ចុប្បន្នភាពទិន្នន័យនិងប្រៀបធៀប (៥) របាការណ៍ហិរញ្ញវត្ថុត្រូវតែសាមញ្ញនិងទាក់ទាញ និង(៦) ផ្សព្វផ្សាយឱ្យដល់អតិថិជនគោលដៅ (Jordan et al., 2016)។

ឆ្នាំ២០០៤ "តម្លាភាព" ត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាយកធ្វើជាសូចនាករមួយ ក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ សូចនាករនេះ (តម្លាភាព) ត្រូវបានកំណត់ក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថាៈ "តម្លាភាព" សំដៅដល់រាល់ច្បាប់ បទប្បញ្ញត្តិ គោលការណ៍ នីតិវិធី និងការអនុវត្តទាំងឡាយ ដែលត្រូវផ្សព្វផ្សាយឱ្យទូលាយសម្រាប់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈ និងសាធារណជន" (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៣, ទំ.៤៥)។

ដោយឡែកតាមការស្រាវជ្រាវ "គណនេយ្យភាព" គឺជាការសម្រេចចិត្តនិងទទួលខុសត្រូវគ្រប់សកម្មភាពអង្គភាពប្រកបដោយតម្លាភាព និងស្របតាមនីតិរដ្ឋ។ គោលនយោបាយគណនេយ្យត្រូវធ្វើឡើងចំពោះភាគីពាក់ព័ន្ធ និយោជិត សហជីព និងសង្គមស៊ីវិល ព្រមទាំងកម្លាំងពលកម្មផងដែរ។ សីលធម៌ សុវត្ថិភាព សុខភាព និងសុខមាលភាពរបស់ពួកគេត្រូវបានការពារចំពោះមុខច្បាប់ និងស្របតាមនីតិរដ្ឋ (Arulrajah, 2016)។ "គណនេយ្យភាព"

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

គឺជាគោលនយោបាយគន្លឹះរបស់រដ្ឋាភិបាលប្រជាធិបតេយ្យ និងជាស្នូលនៃគោលនយោបាយអភិបាលកិច្ចល្អរបស់ខ្លួន។ គណនេយ្យភាពបង្ហាញពី៖ (១) ការទទួលខុសត្រូវរបស់អង្គភាព (២) កាត់បន្ថយអំពើពុករលួយក្នុងអង្គភាព/រដ្ឋាភិបាល (៣) ពន្លឿនផ្នែកសេវាសាធារណៈ (៤) ភាពត្រឹមត្រូវនៃមូលដ្ឋានគតិយុត្តិនិងច្បាប់ (Wirtz and Birkmeyer, 2015)។

ម្យ៉ាងទៀត "គណនេយ្យភាព" ជាសមាសភាពនៃអភិបាលកិច្ច គឺ៖ (១) "គណនេយ្យភាព" ជាគុណធម៌ (Accountability as a Virtue) ដែលផ្ដល់ភាពស្របច្បាប់ទៅមន្ត្រីសាធារណៈ និងអង្គភាពសាធារណៈ ដែលរួមមានតម្លាភាព ភាពជឿទុកចិត្ត សមត្ថភាពចាត់ចែង ទំនួលខុសត្រូវ និងភាពឆ្លើយតបទាន់ពេល និង (២) គណនេយ្យភាពជាយន្តការដែលមានន័យថា ប្រព័ន្ធគណនីត្រូវឆ្លើយទៅនឹងសំណួរពីរជាមូលដ្ឋានគឺ៖ តើនរណាជាតួអង្គបង្ហាញគណនី? និងហេតុអ្វីត្រូវតែបង្កើតគណនី? គណនេយ្យភាពជាយន្តការនៃការសម្រេចចិត្តរបស់អង្គភាព/រដ្ឋាភិបាលក្នុងការបង្កើតឱ្យមានអភិបាលកិច្ចល្អ មាននិន្នាការជានាឱ្យមានគណនេយ្យភាពដល់សាធារណជននិងអង្គភាពសាធារណៈប្រកបដោយគុណធម៌ (Bovens, 2010)។

យោងតាមការសិក្សាផ្នែករដ្ឋបាលសាធារណៈ ឧបករណ៍ធំៗចំនួនប្រាំត្រូវបានប្រើក្នុងការវាស់គណនេយ្យភាពគឺ៖ (១) តម្លាភាព តើយន្តការក្នុងអង្គភាពបង្ហាញជាសាធារណៈឬទេ? (២) ភាពជឿទុកចិត្ត តើយន្តការអង្គភាពមានឧបសគ្គដែរឬទេ? (៣) សមត្ថភាពគ្រប់គ្រង តើអង្គភាពបានដំណើរការតាមគោលនយោបាយ និងនីតិវិធីឬទេ? (៤) ទំនួលខុសត្រូវ តើអង្គភាពអនុវត្តតាមច្បាប់ឬទេ? (៥) ភាពឆ្លើយតបទាន់ពេល តើអង្គភាពសម្រេចបានតាមគោលដៅឬទេ? (Christie, 2017)។ ដូចគ្នាដែរ ឆ្នាំ២០០៤ "គណនេយ្យភាព" ត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យកធ្វើជាសូចនាករមួយទៀតក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ សូចនាករនេះ (គណនេយ្យភាព) ត្រូវបានកំណត់ក្នុងកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈយ៉ាងដូច្នេះថា "គណនេយ្យភាព សំដៅលើការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលចំពោះមុខងារ និងភារកិច្ចដែលទទួលអនុវត្តតាមរយៈប្រព័ន្ធរបាយការណ៍" (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៣, ទំ. ៤៥)។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ឆ្នាំ២០០៤នេះដែរ រាជរដ្ឋាភិបាលចាប់ផ្តើមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមាន ៤ដំណាក់កាល ហើយការបង្កើតគណនេយ្យហិរញ្ញវត្ថុជាដំណាក់កាលទី២ និងការបង្កើតគណនេយ្យភាពចំពោះសមិទ្ធកម្មជាដំណាក់កាលទី៤ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៥)។

ចំណែក "ភាគីពាក់ព័ន្ធ" តាមការសិក្សាស្រាវជ្រាវសំដៅដល់ការចូលរួមដោយផ្ទាល់ ឬតាមរយៈស្ថាប័នអន្តរការីច្បាប់ ឬតាមរយៈតំណាងដែលរកផលប្រយោជន៍រួមជូនអង្គភាព មិនមែនរកផលប្រយោជន៍ជូនបុគ្គលទេ។ ការពិចារណា ការសម្រេចចិត្ត ឬការចូលរួមត្រូវមានការជូនដំណឹង និងរៀបចំជាមុន។ ដំណើរការចូលរួមនេះជាការចូលរួមដោយសេរីភាព និងមានសេរីភាពក្នុងការបញ្ចេញមតិ ព្រមទាំងសេរីភាពនៃការចូលរួមពីសង្គមស៊ីវិល (Arulrajah, 2016)។ រីឯព្រឹត្តិបត្រចុះផ្សាយអន្តរជាតិស្តីពីរដ្ឋាភិបាលបើកចំហ (Open Government: Origin, Development, and Conceptual Perspectives) យើងដកស្រង់បានមូលដ្ឋានបួនធំៗក្នុងការចូលរួមគឺ៖ (១) ផ្តល់ការលើកទឹកចិត្ត (២) ផ្តល់ឱកាសស្មើៗគ្នា (៣) ផ្តល់សេរីភាពក្នុងការសម្រេចចិត្តដោយផ្ទាល់និងដោយប្រយោល និង (៤) ផ្តល់សេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈ (Wirtz & Birkmeyer, 2015)។ ចំពោះរដ្ឋាភិបាលបើកចំហ ការចូលរួមរបស់ពលរដ្ឋជាសមាសធាតុសំខាន់ទីពីរ ពោលគឺការបង្កើតជាយន្តការ និងវិធីសាស្ត្រនៃការចូលរួមរបស់ពលរដ្ឋក្នុងការសម្រេចចិត្តជាសាធារណៈ (Duțu1 & Diaconu, 2017)។

ម្យ៉ាងទៀត តាមចក្ខុវិស័យរបស់ OECD (Organisation for Economic) ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងរដ្ឋាភិបាលជាសាធារណៈត្រូវមានសមាសភាពបីគឺ៖ (១) ការទទួលបានព័ត៌មានគ្រប់គ្រាន់របស់ពលរដ្ឋ (២) ការពិគ្រោះយោបល់ត្រូវធ្វើឡើងតាមមធ្យោបាយទ្វេភាគីរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល និង (៣) ការបង្កើតភាពជាដៃគូរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល (Duțu1 & Diaconu, 2017)។ ម្យ៉ាងទៀតការចូលរួមអាចមានច្រើនរូបភាពដូចជា (១) ការចូលរួមជាមតិយោបល់ (២) ការចូលរួមតាមបណ្តាញផ្សេងៗដូចជាទូរសព្ទ អ៊ីម៉ែលជាដើម (៣) ការជួបប្រជុំដោយផ្ទាល់ និង (៤) ការចូលរួមក្នុងវេទិកាសាធារណៈជាដើម (Cooley, 2010)។

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 Number 2 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

**រូបភាពទី១.** ខ្នាតវង្វាស់តម្លាភាព គណនេយ្យភាព និងភាគីពាក់ព័ន្ធសម្រាប់ការស្រាវជ្រាវ




(កែសម្រួលពីធនាគារពិភពលោក, 2010)

ការចូលរួមដោយប្រយោលគឺ ការចូលរួមតាមប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គមនានាដូចជា ទូរសព្ទ អ៊ីម៉ែលជាដើមត្រូវបានស្នើឡើងដោយឧបករណ៍ចំនួនប្រាំគឺ៖ (១) ការលើកស្ទួយប្រព័ន្ធព័ត៌មាន (២) ការលើកស្ទួយស្វ័យត្រួតពិនិត្យ (self-discovery motive) (៣) ការលើកស្ទួយសមាហរណកម្មសង្គម (social integration motive) (៤) ការលើកស្ទួយការបង្កើនអត្ថប្រយោជន៍សង្គម (social enhancement motive) (៥) ការលើកស្ទួយការកំសាន្ត (Cooley, 2010)។ ទន្ទឹមនឹងនេះដែរ គោលនយោបាយអភិបាលកិច្ចល្អត្រូវបានរាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យភាគីពាក់ព័ន្ធគ្រប់អង្គភាពសាធារណៈ ពិសេស ភាគីពាក់ព័ន្ធនឹងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលរួមមាន៤ផ្នែកគឺ៖ (១) ក្រុមប្រឹក្សាភិបាល (២) ឧត្តមសិក្សា (៣) ឧស្សាហកម្មនិង(៤) ដៃគូអភិវឌ្ឍន៍ផ្នែកអប់រំ។ រាជរដ្ឋាភិបាលជាអ្នកបង្កើតគោលនយោបាយ ផ្ដល់សេវាកម្មដែលមានវិជ្ជាជីវៈ សម្របសម្រួល និងជានិយ័តករយ៉ាងទូលំទូលាយក្នុងវិស័យអប់រំនៅកម្ពុជា។ រាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា និងតាមរយៈនាយកដ្ឋានឧត្តមសិក្សា ជាអ្នកបង្កើតគោលនយោបាយ ដោយត្រូវសម្របសម្រួលជាមួយក្រសួងដទៃក្នុងការបង្កើតគោលនយោបាយធនធានមនុស្ស (Sam & Dhles, 2015)។ យោងតាមការសិក្សាខាងលើ យើងអាចបង្កើតខ្នាតវង្វាស់តម្លាភាព

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

គណនេយ្យភាព និងភាគីពាក់ព័ន្ធសម្រាប់ការស្រាវជ្រាវ ដោយផ្អែកលើទ្រឹស្តីអភិបាលកិច្ចដូចខាងក្រោមនេះ (រូបភាពទី១)។

ម្យ៉ាងទៀត តាមគំរូការិយាធិបតេយ្យដែលបារាំងបន្សល់ទុកនៅក្នុងរដ្ឋបាលអប់រំតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនានានៅកម្ពុជា ភាគីពាក់ព័ន្ធក្នុងការសម្រេចចិត្តនានាត្រូវផ្សារភ្ជាប់ជិតស្និតជាមួយស្ថាប័នរាជរដ្ឋាភិបាល (Sam & Dhles, 2015)។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានផ្តួចផ្តើមអនុវត្តគោលនយោបាយអភិបាលកិច្ចល្អ និងគោលនយោបាយហិរញ្ញប្បទាន ដើម្បីបន្ថយការពឹងផ្អែកលើជំនួយផ្នែកអប់រំ។ សាកលវិទ្យាល័យទាំងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងទាំងសាកលវិទ្យាល័យឯកជនត្រូវធ្វើការតាមដានដោយគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC) ចាប់ពីឆ្នាំ២០០៣មក (Sam & Dhles, 2015)។ នាយកដ្ឋានឧត្តមសិក្សាដើរតួជាអ្នកសម្របសម្រួលក្នុងការរៀបចំគោលនយោបាយអប់រំ កំណែទម្រង់កម្មវិធីសិក្សា។ ដៃគូអភិវឌ្ឍន៍រួមទាំងម្ចាស់ជំនួយទ្វេភាគីអន្តរជាតិ ភ្នាក់ងារនិងម្ចាស់ជំនួយពហុភាគីដូចជា ភ្នាក់ងារអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងហាភាពអឺរ៉ុបជាដើម (Sam & Dhles, 2015)។

## វិធីសាស្ត្រស្រាវជ្រាវ

គ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយត្រូវបានជ្រើសរើសជាតំបន់គោលដៅក្នុងការស្រាវជ្រាវលើប្រធានបទ "ខ្នាតវង្វាស់តម្លាភាព គណនេយ្យភាព និងភាគីពាក់ព័ន្ធក្នុងការប្រើប្រាស់ថវិកាកម្មវិធី (PB) នៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយក្នុងព្រះរាជាណាចក្រកម្ពុជាដោយផ្អែកលើទ្រឹស្តីអភិបាលកិច្ចល្អ"។ អ្នកចូលរួមឆ្លើយកម្រងសំណួរមានចំនួន ១០៦នាក់ មកពីគ្រប់មហាវិទ្យាល័យ វិទ្យាស្ថាន និងបណ្ណាល័យនៃសាកលវិទ្យាល័យ។

### ការប្រមូលទិន្នន័យ

ទិន្នន័យដែលត្រូវប្រមូលមានពីរប្រភេទគឺទិន្នន័យបន្ទាប់បន្សំ និងទិន្នន័យដើម។ ទិន្នន័យបន្ទាប់បន្សំត្រូវបានប្រមូលពីក្រសួងអប់រំ យុវជន និង កីឡា (EMIS) អង្គការជាតិ អង្គការអន្តរជាតិ (ធនាគារពិភពលោក & ធនាគារអភិវឌ្ឍអាស៊ី) និងអត្ថបទក្នុងទស្សនាវដ្តីស្រាវជ្រាវ ដើម្បីយកជាមូលដ្ឋានរំលឹកទ្រឹស្តីពាក់ព័ន្ធ និងជាមូលដ្ឋានផ្ទៀងផ្ទាត់នឹងទិន្នន័យដើមដែលប្រមូលបាន។

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 Number 2 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ការប្រមូលទិន្នន័យដើម៖ កម្រងសំណួរផ្លូវការ (Structured Questionnaires) ត្រូវបានបង្កើតដោយមានសំណួរបិត និងសំណួរបើក ដើម្បីប្រមូលទិន្នន័យបែបបរិមាណវិស័យ ទាក់ទងនឹងអភិបាលកិច្ចហិរញ្ញវត្ថុ ដែលអនុវត្តដោយគណៈគ្រប់គ្រង មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងការិយាល័យនីមួយៗ។ ការប្រមូលទិន្នន័យបរិមាណវិស័យនេះអាចឱ្យយើងវិភាគបែបស្ថិតិ ដែលមានសារសំខាន់សម្រាប់អ្នកធ្វើផែនការ និងអ្នកធ្វើគោលនយោបាយ។ បន្ទាប់មក កម្រងសំណួរត្រូវបានចែកជូនអ្នកចូលរួមឆ្លើយសំណួរបំពេញដោយខ្លួនឯង។ ការប្រើវិធីសាស្ត្របែបនេះ អាចឱ្យអ្នកចូលរួមឆ្លើយសំណួរបានបញ្ចេញយោបល់ដោយសេរីជាលក្ខណៈអាណាមឹក។

**ការវិភាគទិន្នន័យ**

ក្នុងការសិក្សានេះ ស្មេរបានប្រើវិធីសាស្ត្រវិភាគបែបបរិមាណវិស័យ និងបែបគុណវិស័យ។ ការវិភាគទិន្នន័យបែបគុណវិស័យគឺវិភាគតាមចំណងជើងនិងតាមបញ្ហា។ ស្មេរធ្វើការវិភាគដោយផ្អែកលើទិន្នន័យបន្ទាប់បន្សំ និងឯកសារស្រាវជ្រាវដែលមានស្រាប់។ ការវិភាគនេះជួយឱ្យយើងយកទិន្នន័យដែលមានស្រាប់ ក៏ដូចជាទិន្នន័យបន្ទាប់បន្សំ មកផ្ទៀងផ្ទាត់ជាមួយទិន្នន័យដើម ដែលបានមកពីការអង្កេត។ ការវិភាគរកបញ្ហាក៏អាចជួយឱ្យយើងដឹងពីឫសគល់ និងប្រភពនៃបញ្ហាដែលជួបប្រទះដោយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនៅកម្ពុជាដែរ។

ចំពោះការវិភាគទិន្នន័យបែបបរិមាណវិស័យវិញ ស្មេរបានប្រើទាំងការវិភាគបែបស្ថិតិ និងពណ៌នាបែបស្ថិតិ (Descriptive Statistic Analysis) ដែលអាចរកឃើញភាពញឹកញាប់ (Frequency) និងភាគរយទាក់ទងនឹងសូចនាករមួយចំនួនដូចជាប្រភេទតួនាទី ប្រភេទនៃការចំណាយ ប្រភេទចំណូល និងប្រភពថវិកាជាដើម។ ចំណែកការវិភាគទស្សនៈ និងភាពពេញចិត្តលើអភិបាលកិច្ច គណនេយ្យភាព តម្លាភាព និងការចូលរួមក្នុងការគ្រប់គ្រងថវិកាកម្មវិធីនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈត្រូវបានវាស់ស្ទង់ជា ៥កម្រិត គឺ៖ ខ្ពស់ណាស់ ខ្ពស់ មធ្យម ទាប និងទាបណាស់។

**លទ្ធផលស្រាវជ្រាវ**

តាមការស្រាវជ្រាវនិងវិភាគដោយប្រើឧបករណ៍វិភាគខាងលើ របកគំឃើញនៃខ្នាតរង្វាស់ពីតម្លាភាព និងគណនេយ្យភាពនៃការប្រើប្រាស់ថវិកាកម្មវិធី ដោយផ្អែកលើទ្រឹស្តីអភិបាលកិច្ច ត្រូវបានបង្ហាញក្នុងតារាងទី១ និងរង្វាស់ពីភាគីពាក់ព័ន្ធត្រូវបានបង្ហាញក្នុងតារាងទី២។

**ខ្នាតរង្វាស់តម្លាភាពនិងគណនេយ្យភាពដោយផ្អែកលើទ្រឹស្តីអភិបាលកិច្ចល្អ**

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

តារាងទី១ខាងក្រោមនេះបង្ហាញពីខ្នាតរង្វាស់តម្លាភាពនិងគណនេយ្យភាពនៃការប្រើប្រាស់ថវិកាកម្មវិធី (PB) គ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយ។ សូចនាករសរុប ចំនួន២២ ត្រូវបានប្រើជាខ្នាតរង្វាស់នេះ។ ការវិភាគបានបង្ហាញថា តម្លាភាពនៃការប្រើប្រាស់ថវិកាកម្មវិធីនៅអង្គភាពសាមីនៅមានកម្រិតនៅឡើយ ព្រោះតម្លៃ *M* (២.៧៧) បង្ហាញលើសពីពាក់កណ្ដាល សម្ដែងការមិនពេញចិត្តចំពោះសមាសភាពទាំងពីរនេះ (តម្លាភាពនិងគណនេយ្យភាព) ដែលតម្រូវឱ្យអង្គភាពថវិកាបញ្ចេញនូវរាល់ព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យចាំបាច់ឱ្យដល់មន្ត្រីក្រោមឱវាទដឹងដោយគ្មានការលាក់បាំង។ ម្យ៉ាងទៀត គ្រប់ប្រតិបត្តិការណ៍ចំណូល-ចំណាយរបស់អង្គភាពថវិកាសាមី គួរត្រូវបានបង្ហាញដល់មន្ត្រីក្រោមឱវាទយ៉ាងហោចណាស់ត្រឹមគណៈគ្រប់គ្រងថ្នាក់កណ្ដាលដែរ។ ម្យ៉ាងទៀត ការប្រៀបធៀបតម្លៃ *M* និងមធ្យមភាគជាភាគរយបានបង្ហាញថា ភាពពេញចិត្ត និងភាពពេញចិត្តទាំងស្រុងមានត្រឹមតែ ៤០.៩៧% ប៉ុណ្ណោះ។ លទ្ធផលក្រោម ៥០% នេះបង្ហាញពីការមិនសប្បាយចិត្តរបស់ពួកគាត់ ព្រោះលទ្ធផលដែលបានពីតម្លៃខ្នាតរង្វាស់ ក៏ដូចជាការប្រាប់ពីការប្រើប្រាស់ថវិកាកម្មវិធីទាក់ទងនឹងគោលការណ៍តម្លាភាព និងគណនេយ្យភាពនៅអង្គភាពថវិកាសាមី នៅមានកម្រិតនៅឡើយ។ ជាគោលការណ៍ អង្គភាពថវិកាសាមីគួរកាត់បន្ថយនូវការលាក់បាំងព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យចាំបាច់ ហើយបង្កើននូវការផ្សាយពីលំហូរប្រតិបត្តិការណ៍ហិរញ្ញវត្ថុ និងគណនេយ្យឱ្យឆ្លើយតបតាមការចង់បាន។

## ខ្នាតរង្វាស់ពីភាគីពាក់ព័ន្ធដោយផ្អែកលើទ្រឹស្ដីអភិបាលកិច្ចល្អ

តារាងទី២ខាងក្រោមនេះបង្ហាញអំពីខ្នាតរង្វាស់ភាគីពាក់ព័ន្ធនៃការប្រើប្រាស់ថវិកាកម្មវិធី (PB) គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនោះ។ សូចនាករសរុប ចំនួន៩ ត្រូវបានប្រើជាខ្នាតសម្រាប់វាស់ភាគីពាក់ព័ន្ធ។ លទ្ធផលនៃការវិភាគបង្ហាញថា អ្នកឆ្លើយសំណួរច្រើនជាង ៥០% សម្ដែងការមិនពេញចិត្តចំពោះសមាសភាគមួយនេះ (ភាគីពាក់ព័ន្ធ) ព្រោះតម្លៃ *M* (២.៧៨) បង្ហាញថា ភាគីពាក់ព័ន្ធមិនត្រូវបានអនុញ្ញាតិឱ្យចូលរួមពេញលេញក្នុងការសម្រេចចិត្តនានាទាក់ទងនឹងថវិកាកម្មវិធីទេ ហើយការសម្រេចចិត្តទាក់ទងនឹងថវិកាកម្មវិធីនេះបន្តធ្វើឡើងជាកញ្ចប់ថវិការដ្ឋបាល។ ម្យ៉ាងទៀត លទ្ធផលនៃការវិភាគដែលបង្ហាញខ្នាតរង្វាស់ក្រោម ៥០% (៤៣.៨៣%) បង្ហាញភាពមិនពេញចិត្ត និងភាពមិនពេញចិត្តទាំងស្រុង ព្រោះការសម្រេច

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ចិត្តទាំងឡាយទាក់ទងនឹងថវិកាកម្មវិធីដោយគ្មានវត្តមានរបស់ពួកគាត់ ឬការមិនផ្តល់ការសម្រេចចិត្តពេញលេញដល់ពួកគាត់។

## **ការពិភាក្សា**

ទ្រឹស្តីរបស់លោក Downley ឆ្នាំ២០០៦ បានលើកឡើងថា ដើម្បីឱ្យការគ្រប់គ្រងថវិកាមានអភិបាលកិច្ចល្អ ការប្រើប្រាស់ថវិកាត្រូវមានដោយយន្តការ ហើយយន្តការដែលបានដាក់ចេញក្នុងការរកមើលតម្លាភាពក្នុងការប្រើប្រាស់ថវិកានោះគឺៈ (១) ពិភាក្សាអំពីថវិកាដែលបានគ្រោងទុកជាមួយអង្គការសង្គមស៊ីវិល (២) រៀបចំវេទិកាថវិកាសាធារណៈ (៣) ផ្សព្វផ្សាយសេចក្តីព្រាងថវិកាមុនពេលក្រុមប្រឹក្សាក្រុងបានបោះឆ្នោតសម្រេច (៤) បង្កើតប្រព័ន្ធព័ត៌មានថវិកាក្នុងអង្គភាព/តំបន់ (៥) បង្កើតវេទិកាសាធារណៈកញ្ចប់ថវិការបស់រដ្ឋបាល និង (៦) បង្ហាញកញ្ចប់ថវិកាដែលបានអនុម័តធៀបនឹងឆ្នាំចាស់។ ម្យ៉ាងទៀត តាមព្រឹត្តិបត្ររបស់ លោក Wirtz and Birkmeyer ឆ្នាំ២០១៥ ស្តីពីរដ្ឋាភិបាលបើកចំហ សមាសភាគដែលនាំឱ្យមានតម្លាភាពថវិកាមានបីធំៗគឺៈ (១) ការបង្កើតប្រព័ន្ធព័ត៌មាននិងចេញផ្សាយឱ្យទាន់ពេលវេលា (២) ប្រសិទ្ធភាពតាមផ្លូវច្បាប់ និង (៣) ប្រសិទ្ធភាពសង្គមស៊ីវិលតាមរយៈការផ្តល់សេវាសាធារណៈ។

ម្យ៉ាងទៀត លោក Wirtz and Birkmeyer ឆ្នាំ២០១៥ "គណនេយ្យភាព" គឺជាគោលនយោបាយគន្លឹះរបស់រដ្ឋាភិបាលប្រជាធិបតេយ្យ និងជាស្នូលនៃគោលនយោបាយអភិបាលកិច្ចល្អរបស់ខ្លួន។ គណនេយ្យភាពបង្ហាញពីៈ (១) ការទទួលខុសត្រូវរបស់អង្គភាព (២) ការកាត់បន្ថយអំពើពុករលួយក្នុងអង្គភាព/រដ្ឋាភិបាល (៣) ការពន្លឿនផ្នែកសេវាសាធារណៈ (៤) ភាពត្រឹមត្រូវនៃមូលដ្ឋានគតិយុត្តិនិងច្បាប់។ ដោយឡែក ការវិភាគបានបង្ហាញថា តម្លាភាពនៃការប្រើប្រាស់ថវិកាកម្មវិធីនៅអង្គភាពថវិកាសាមីនៅមានកម្រិតនៅឡើយ ព្រោះតម្លៃ *M* (២.៧៧) មានន័យថា ជាងពាក់កណ្តាលសម្តែងការមិនសប្បាយចិត្តចំពោះសូចនាករមួយនេះ និងមធ្យមភាគជាភាគរយបង្ហាញថា ភាពពេញចិត្តនិងភាពពេញចិត្តទាំងស្រុងមានត្រឹមតែ ៤០.៩៧% ប៉ុណ្ណោះ។ ដូច្នេះ បើពិនិត្យទ្រឹស្តីរបស់លោក Downley ឆ្នាំ២០០៦ ត្រង់ចំណុចទី១ យន្តការនៃការប្រើប្រាស់ថវិកាកម្មវិធីនៅមានកម្រិត ដោយអង្គភាពមិនបានធ្វើការពិភាក្សាឱ្យបានទូលាយជាមួយមន្ត្រីក្រោមឱវាទ។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ចំណែកចំណុចទី២ ក៏អង្គភាពរៀបចំគម្រោងថវិកាដោយមិនបានធ្វើវេទិកាសាធារណៈដែរ។ រីឯចាប់ពីចំណុចទី៣ដល់ទី៦នៃទ្រឹស្តីខាងលើ ក៏អង្គភាពមិនបានអនុវត្តឱ្យបានពេញលេញផងដែរ។ ទន្ទឹមនឹងនោះដែរ ការទទួលខុសតាមផ្នែករបស់អង្គភាពថវិកាមិនទាន់មានភាពច្បាស់លាស់ ភាពមិនប្រក្រតីក្នុងការប្រើប្រាស់ថវិកាមិនត្រូវបានលាតត្រដាងឱ្យទូលាយ និងសេវាសាធារណៈរបស់អង្គភាពថវិកាមានភាពស្លឹកស្រពន់ ដែលមានន័យថា តម្លាភាពនិងគណនេយ្យភាពនៃការប្រើប្រាស់ថវិកាកម្មវិធីនៅមានកម្រិត ដែលបណ្តាលឱ្យអភិបាលកិច្ចពុំមានភាពល្អប្រសើរ។

រីឯរបកគំហើញរបស់ លោក Wirtz & Birkmeyer ឆ្នាំ២០១៥ ព្រឹត្តិបត្រអន្តរជាតិស្តីពីរដ្ឋាភិបាលបើកចំហ យើងស្រង់បានមូលដ្ឋានធំៗចំនួន ៤ ក្នុងការចូលរួមគឺ៖ (១) ផ្តល់ការលើកទឹកចិត្ត (២) ផ្តល់ឱកាសស្មើៗគ្នា (៣) ផ្តល់សេរីភាពក្នុងការសម្រេចចិត្តដោយផ្ទាល់ និងមិនផ្ទាល់ (៤) ផ្តល់សេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈ។ ដោយឡែក លទ្ធផលនៃការវិភាគបានបង្ហាញថា អ្នកឆ្លើយសំណួរច្រើនជាង ៥០% សម្តែងការមិនពេញចិត្តចំពោះសមាសភាគមួយនេះ (ភាគីពាក់ព័ន្ធ)។ បើប្រៀបធៀបរបកគំហើញនេះនឹងរបកគំហើញរបស់លោក Wirtz & Birkmeyer ឆ្នាំ២០១៥ យើងឃើញថា ការលើកទឹកចិត្ត ការផ្តល់ឱកាសស្មើគ្នា ការផ្តល់សេរីភាពក្នុងការសម្រេចចិត្ត និងការផ្តល់សេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈនៅមានកម្រិត។ ដូច្នេះ ការសម្រេចចិត្តពីភាគីពាក់ព័ន្ធក្នុងអង្គភាពថវិកាក៏នៅមានកម្រិតដែរ ដែលជាហេតុបណ្តាលឱ្យអភិបាលកិច្ចពុំមានភាពល្អប្រសើរផងដែរ។

**កម្រិតនៃការជឿជាក់នៃការវិភាគទិន្នន័យ** (Cronobach's Alpha)

ដើម្បីវិភាគកម្រិតនៃភាពជឿកជាក់ (Cronobach's Alpha) ស្មេរប្រើកម្រងសំណួរដែលមានសូចនាករសរុប ចំនួន៣១ ដែលត្រូវបានបែងចែកជាពីរផ្នែកគឺ៖ (១) សូចនាករស្តីពីតម្លាភាពនិងគណនេយ្យភាពនៃការប្រើប្រាស់ថវិកា ចាប់ពីសំណួរទី១ដល់ទី២២ក្នុងតារាងទី១ និង (២) សូចនាករស្តីពីភាគីពាក់ព័ន្ធ ចាប់ពីសំណួរទី១ដល់ទី២២ក្នុងតារាងទី២។ ស្មេរបានពិភាក្សាយ៉ាងល្អិតល្អន់ទៅលើកម្រងសំណួរនេះ មុននឹងយកទៅប្រើក្នុងការសម្ភាស និងបានធ្វើ Cronobach's Alpha តេស្ត ដែលចេញលទ្ធផលអាចទទួលយកបានដូចបង្ហាញក្នុងតារាងទី៣ខាងក្រោមនេះ។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ការធ្វើ Cronobach´s Alpha តេស្តក្នុងតារាងទី៣នេះបង្ហាញថា៖ (១) ដំណាក់កាលទី១ គោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុនិងគណនេយ្យ ចំនួន០៦សំណួរ មានតម្លៃ០.៧៥ (២) ដំណាក់កាលទី២ តម្លាភាពនិងគណនេយ្យភាព ចំនួន២២សំណួរ មានតម្លៃ០.៨២ (៣) ដំណាក់កាលទី៣ ការចូលរួមពីភាគីពាក់ព័ន្ធ ចំនួន០៩សំណួរ មានតម្លៃ០.៨២ និង (៤) ដំណាក់កាលទី៤ ប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី ចំនួន០៦សំណួរ មានតម្លៃ ០.០៣។ តាមគោលការណ៍ Cronobach's Alpha ចំពោះតម្លៃ Cronobach's Alpha ចាប់ពី ០.៧ ឡើងទៅជាតម្លៃវិជ្ជមាន ដែលអាចទទួលយកបាន (Worl Bank, 2010)។

**តារាងទី៣. បង្ហាញលទ្ធផលនៃការធ្វើតេស្ត**

| សមាសភាគ | ចំនួនសំណួរ | Cronobach's Alpha |
|---|---|---|
| តម្លាភាពនិងគណនេយ្យភាព | 22 | 0.82 |
| ការចូលរួមពីភាគីពាក់ព័ន្ធ | 9 | 0.72 |

## សេចក្តីសន្និដ្ឋាន

ក្នុងផ្នែកខ្នាតវាស់ពីតម្លាភាពនិងគណនេយ្យភាពនៃការប្រើប្រាស់ថវិកាកម្មវិធី យើងបានប្រើសូចនាករដល់ទៅ២២។ ផ្អែកលើលទ្ធផលនៃការវិភាគនេះ យើងអាចសន្និដ្ឋានបានថា តម្លាភាពនិងគណនេយ្យភាពនៃការអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកាមួយនេះនៅមានកម្រិត ព្រោះអ្នកឆ្លើយសំណួរច្រើនលើសលប់សម្តែងការមិនសប្បាយចិត្តចំពោះការមិនបង្ហាញព័ត៌មានហិរញ្ញវត្ថុនិងគណនេយ្យឱ្យបានទូលាយ ជាហេតុនាំឱ្យមានការសង្ស័យក្នុងអង្គភាពថវិកា។

ក្នុងការវាស់ផ្នែកភាគីពាក់ព័ន្ធ យើងបានប្រើសូចនាករចំនួន០៩។ យោងតាមលទ្ធផលនៃការវាស់ យើងអាចសន្និដ្ឋានបានថា ផ្នែកភាគីពាក់ព័ន្ធកម្រិតកណ្តាលពុំត្រូវបានអនុញ្ញាតិឱ្យចូលរួមសម្រេចចិត្តពេញលេញក្នុងការរៀបចំផែនការថវិកា និងការអនុម័តថវិកាឱ្យទូលាយនោះទេ។ សកម្មភាពទាំងនេះធ្វើឡើងត្រឹមថ្នាក់គណៈគ្រប់គ្រងជាន់ខ្ពស់ និងផ្នែករដ្ឋទេយ្យតែប៉ុណ្ណោះ។

## សេចក្តីថ្លែងអំណរគុណ

លោក ប៉ិញ សឿន បេក្ខជនបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៃសាកលវិទ្យាល័យវេស្ទើន សូមគោរពថ្លែងអំណរគុណចំពោះគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យវេស្ទើនដែលបានផ្តល់

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតដល់រូបខ្ញុំបាទប្រកបដោយគុណភាព និងគុណវឌ្ឍិដែលអាចទទួលយកបាន។ ជាងនេះទៅទៀត ខ្ញុំបាទសូមគោរពសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានផ្តល់ឱកាសឱ្យខ្ញុំបាទបានសិក្សារៀនសូត្រ និងអនុញ្ញាតិឱ្យខ្ញុំបាទបានប្រមូលទិន្នន័យសំខាន់ៗពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មរបស់ខ្ញុំបាទ។ មិនតែប៉ុណ្ណោះ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជាអនេកកប្បការចំពោះ ឯកឧត្តម លោកជំទាវ និងអស់លោក-លោកស្រី ដែលជាគណៈនិពន្ធនាយកនៃ the Cambodia Journal of Basic and Applied Research (CJBAR) ដែលបានទទួលយកអត្ថបទស្រាវជ្រាវរបស់ខ្ញុំបាទមកបោះពុម្ពក្នុងទស្សនាវដ្តីនេះ។ ជាថ្មីម្តងទៀត ខ្ញុំបាទសូមគោរពសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះសាស្ត្រាចារ្យណែនាំទាំងពីររូប ដែលបានលះបង់ពេលវេលាដ៏មានតម្លៃបំផុតរបស់លោកក្នុងការដឹកនាំនិក្ខេបទរបស់ខ្ញុំបាទនេះ តាំងពីរដើមរៀងមករហូតទទួលបានជោគជ័យ។

## ឯកសារយោង

UNESCO (២០១៥). វិស័យអប់រំឆ្នាំ២០៣០ សេចក្តីប្រកាសទីក្រុង Incheon និងក្របខណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។ ក្រសួងមហាផ្ទៃ អភិបាលកិច្ចល្អ បោះពុម្ពលើកទី៤ ខែកុម្ភៈ ឆ្នាំ២០១៣.

រាជរដ្ឋាភិបាលកម្ពុជា, (២០១៨). យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា.

សម្តេចព្រះសង្ឃរាជ ជួន ណាត, (១៩៦៧). វចនានុក្រមខ្មែរ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥.

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២០១៣). កម្រងសម្រង់ បទប្បញ្ញត្តិច្បាប់សំខាន់ៗទាក់ទងនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សានីតិកម្ម.

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២០១៥). ការប្រើលើកដំបូងនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (First-time Adoption of Cambodian International Financial Reporting Standards/CIFRS 1) ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ.

Amsler, L. B., & Sherrod, J. (2017). Accountability Forums and Dispute System Design. *Public Performance & Management Review*, *40*(3), 529-550.

Arulrajah, A. A. (2016). Literature review on good governance in the organizations through human resource management: A corporate level analysis. *International Business Research*, *9*(8), 14.

Bano, S., & Taylor, J. (2015). Universities and the knowledge-based economy: Perceptions from a developing country. *Higher Education Research & Development*, *34*(2), 242-255.

Boer, H. D., & Goedegebuure, L. (2007). 'Modern'governance and codes of conduct in Dutch higher education. *Higher Education Research & Development*, *26*(1), 45-55.

Bovens, M. (2010). Two Concepts of Accountability: Accountability as a Virtue and as a Mechanism. *West European Politics*, *33*(5), 946-967.

Brun-Martos, M. I., & Lapsley, I. (2017). Democracy, governmentality and transparency: participatory budgeting in action. *Public Management Review*, *19*(7), 1006-1021.

Brun-Martos, M. I., & Lapsley, I. (2017). Democracy, governmentality and transparency: participatory budgeting in action. *Public Management Review*, *19*(7), 1006-1021.

Christie, N. V. (2018). A Comprehensive Accountability Framework for Public Administrators. *Public Integrity*, *20*(1), 80-92.

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

Clayton, T. (2005). Re-orientations in moral education in Cambodia since 1975. *Journal of moral education*, *34*(4), 505-517.

Dowley, K. M. (2006). Local government transparency in east central Europe. *Local Government Studies*, *32*(5), 563-583.

Duţu, A., & Diaconu, M. (2017). Community participation for an open public administration: Empirical measurements and conceptual framework design. *Cogent Business & Management*, *4*(1), 1287980.

Eccleston, R., & Stubbs, R. (2016). Public Sector Participation and Compliance across National and Global Transparency Regimes. *International Journal of Public Administration*, *39*(10), 758-770.

Fergusson, L. C., & Masson, G. L. (1997). A culture under siege: post-colonial higher education and teacher education in Cambodia from 1953 to 1979. *History of Education*, *26*(1), 91-112.

Jordan, M. M., Yusuf, J. E., Berman, M., & Gilchrist, C. (2017). Popular Financial Reports as Fiscal Transparency Mechanisms: An Assessment Using the Fiscal Transparency Index for the Citizen User. *International Journal of Public Administration*, *40*(8), 625-636.

Juy Pheng, Hang Sovonn and Yos Soly, (2001). International Institute for Educational Planning Inancial Management of Education Systems *Educational Financing and Budgeting in Cambodia*

Madupu, V., & Cooley, D. O. (2010). Antecedents and consequences of online brand community participation: A conceptual framework. *Journal of Internet Commerce*, *9*(2), 127-147.

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

Maldonado, N. (2010, May). The World Bank's evolving concept of good governance and its impact on human rights. In *Doctoral workshop on development and international organizations, Stockholm, Sweden, May* (pp. 29-30).

Power, E. J., & Handley, J. (2017). A best-practice model for integrating interdisciplinarity into the higher education student experience. *Studies in Higher Education*, 1-17.

Rappleye, J., & Un, L. (2018). What drives failed policy at the World Bank? An inside account of new aid modalities to higher education: context, blame, and infallibility. *Comparative Education*, *54*(2), 250-274.

Sam, C., & Dahles, H. (2017). Stakeholder involvement in the higher education sector in Cambodia. *Studies in Higher Education*, *42*(9), 1764-1784.

Sen, V. (2017). Hybrid governmentality: higher education policymaking in post-conflict Cambodia. *Studies in Higher Education*, 1-13.

Spicer, Z. (2017). Bridging the accountability and transparency gap in inter-municipal collaboration. *Local Government Studies*, *43*(3), 388-407.

The World Bank, (2010). Directions in Development, Human Development, *Financing Higher Education in Africa*.

Tripathi, K. D. (2013). *Essentials of medical pharmacology*. JP Medical Ltd.

Weiss, T. G. (2000). Governance, good governance and global governance: conceptual and actual challenges. *Third world quarterly*, *21*(5), 795-814.

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

Wirtz, B. W., & Birkmeyer, S. (2015). Open government: Origin, development, and conceptual perspectives. *International Journal of Public Administration*, *38*(5), 381-396.

Zimic, D. (1982). Yugoslav Universities and Developing Countries. *Higher Educattion in Europe*, *7*(1), 13-16.

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

# ឧបសម្ព័ន្ធ

**តារាងទី១.** ខ្នាតរង្វាស់ពីតម្លាភាពនិងគណនេយ្យភាពនៃការប្រើប្រាស់ថវិកាកម្មវិធី

| ល.រ | បរិយាយ | *M* | *SD* |
|---|---|---|---|
| 1 | តើអ្នកពេញចិត្តកម្រិតណាចំពោះការឆ្លើយតបនៃថវិកាដែលស្នើសុំទាំងអស់ទៅនឹងផែនការសកម្មភាពរបស់ដេប៉ាតឺម៉ង់/ការិយាល័យរបស់អ្នក ? | 2.83 | 1.12 |
| 2 | តើអ្នកពេញចិត្តកម្រិតណាចំពោះថវិកាដែលបានពីការស្នើសុំត្រូវបានយកមកអភិវឌ្ឍសម្រាប់បុគ្គលអប់រំនៅដេប៉ាតឺម៉ង់/ការិយាល័យរបស់អ្នក ? | 2.78 | 1.12 |
| 3 | តើអ្នកពេញចិត្តកម្រិតណាចំពោះការឆ្លើយតបដែលមានកម្រិតភាគរយទាបធៀបនឹងការស្នើសុំ ? | 3.26 | 1.11 |
| 4 | តើអ្នកពេញចិត្តកម្រិតណាចំពោះការឆ្លើយតបដែលមានកម្រិតភាគរយមធ្យមធៀបនឹងការស្នើសុំ ? | 3.12 | 0.75 |
| 5 | តើអ្នកពេញចិត្តកម្រិតណាចំពោះការស្នើសុំដែលមានការឆ្លើយតបក្នុងកម្រិតមួយរយភាគរយ ? | 2.63 | 1.34 |
| 6 | តើអ្នកពេញចិត្តកម្រិតណាចំពោះឯកសារដែលអង្គភាពថវិកាតម្រូវឱ្យអ្នកទូទាត់ត្រឡប់វិញ ? | 2.92 | 1.03 |
| 7 | តើអ្នកពេញចិត្តកម្រិតណាចំពោះការតម្រូវមានឯកសារសងត្រឡប់គ្រប់លក្ខខណ្ឌរបស់អង្គភាពថវិកា ? | 2.86 | 0.97 |
| 8 | តើអ្នកមានចិត្តកម្រិតណាចំពោះការតម្រូវឱ្យមានការដេញថ្លៃសម្រាប់គម្រោងចំណាយប្រចាំឆ្នាំរបស់អង្គភាពថវិកា ? | 2.71 | 1.19 |
| 9 | តើអ្នកពេញចិត្តកម្រិតណា ប្រសិនបើការឆ្លើយតបសំណើសុំថវិការបស់អ្នកមានការយឺតយ៉ាវ ? | 3.36 | 1.11 |

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 Number 2 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

| | | | |
|---|---|---|---|
| 10 | តើអ្នកពេញចិត្តកម្រិតណា ប្រសិនបើព័ត៌មានហិរញ្ញវត្ថុនិងគណនេយ្យត្រូវបានផ្សព្វផ្សាយទូលំទូលាយក្នុងអង្គភាពថវិកា ? | 2.25 | 1.19 |
| 11 | តើអ្នកពេញចិត្តកម្រិតណា បើព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យត្រូវបានផ្សព្វផ្សាយត្រឹមកម្រិតគណៈគ្រប់គ្រងអង្គភាពថវិកា ? | 2.95 | 1.01 |
| 12 | តើអ្នកពេញចិត្តកម្រិតណា ប្រសិនបើព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យត្រូវបានផ្សព្វផ្សាយដោយប្រព័ន្ធអេឡិចត្រូនិច ? | 2.29 | 1.11 |
| 13 | តើអ្នកពេញចិត្តកម្រិតណាចំពោះប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុបែបប្រពៃណីកន្លងមក ? | 3.58 | 1.03 |
| 14 | តើអ្នកពេញចិត្តកម្រិតណាចំពោះព័ត៌មានហិរញ្ញវត្ថុដែលគ្រប់គ្រងនិងផ្សព្វផ្សាយដោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុអេឡិចត្រូនិច ? | 2.27 | 1.07 |
| 15 | តើអ្នកពេញចិត្តកម្រិតណា បើបុគ្គលិកអប់រំបម្រើការនៅផ្នែកហិរញ្ញវត្ថុនិងគណនេយ្យមិនមានជំនាញពិតប្រាកដ ? | 3.75 | 1.17 |
| 16 | តើអ្នកពេញចិត្តកម្រិតណា បើបុគ្គលិកអប់រំបម្រើការនៅផ្នែកហិរញ្ញវត្ថុនិងគណនេយ្យមានជំនាញពិតប្រាកដ ? | 2.17 | 1.28 |
| 17 | តើអ្នកពេញចិត្តកម្រិតណាចំពោះការកៀរគរចំណូល-ចំណាយឱ្យចេញចូលតាមច្រកតែមួយ ? | 2.19 | 1.16 |
| 18 | តើអ្នកពេញចិត្តកម្រិតណាចំពោះដំណើរការស្នើសុំថវិកាដែលតម្រូវឱ្យឆ្លងកាត់ការអនុញ្ញាតិគ្រប់ភាគីពាក់ព័ន្ធ ? | 2.80 | 0.99 |
| 19 | តើអ្នកពេញចិត្តកម្រិតណា បើតម្រូវឱ្យមានការត្រួតពិនិត្យផ្ទៃក្នុងមុននឹងស្នើសុំថវិការបស់ដេប៉ាតឺម៉ង់សាមី/ការិយាល័យសាមី ? | 2.68 | 0.98 |
| 20 | តើអ្នកពេញចិត្តកម្រិតណាចំពោះក្រុមដេញថ្លៃនៃគម្រោងស្នើសុំគ្រប់កូតារបស់ដេប៉ាតឺម៉ង់សាមី/ការិយាល័យសាមី ? | 2.93 | 0.94 |

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

| | | | |
|---|---|---|---|
| 21 | តើអ្នកពេញចិត្តកម្រិតណា បើតម្រូវឱ្យអង្គភាពថវិការបស់អ្នកមាន ស្តង់ដារហិរញ្ញវត្ថុ និងគណនេយ្យរបស់អង្គភាពផ្ទាល់ ដោយអនុទ្បោមតាមស្តង់ដាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ? | 2.26 | 1.11 |
| 22 | តើអ្នកពេញចិត្តកម្រិតណា បើតម្រូវឱ្យមានការធ្វើសវនកម្មជាប្រចាំដល់ អង្គភាពថវិកា? | 2.27 | 1.16 |
| សរុបជាមធ្យម | | 2.77 | 1.04 |

**<u>ចំណាំ៖</u>** ខ្នាតរង្វាស់ពី ១ ដល់ ៥ (១ = ពេញចិត្តទាំងស្រុង, ៥ = មិនពេញចិត្តទាំងស្រុង)
*M = គិតជាមធ្យម, SD = គម្លាតស្តង់ដា*

**តារាងទី២**. ខ្នាតរង្វាស់ផ្នែកភាគីពាក់ព័ន្ធ

| ល.រ | បរិយាយ | *M* | *SD* |
|---|---|---|---|
| 1 | តើអ្នកពេញចិត្តកម្រិតណា បើអ្នកមិនតម្រូវឱ្យចូលរួមសម្រេចចិត្តទូលំទូលាយផ្នែកគម្រោងថវិកាកម្មវិធីរបស់អង្គភាពថវិកា? | 3.2 | 1.08 |
| 2 | តើអ្នកពេញចិត្តកម្រិតណា បើអ្នកតម្រូវឱ្យចូលរួមសម្រេចចិត្តទូលំទូលាយផ្នែកគម្រោងថវិកាកម្មវិធីរបស់អង្គភាពថវិកា? | 2.35 | 1.03 |
| 3 | តើអ្នកពេញចិត្តកម្រិតណា បើគម្រោងនៃថវិកាកម្មវិធីត្រូវបានសម្រេចត្រឹមគណៈគ្រប់គ្រងអង្គភាពថវិកា? | 3 | 0.96 |
| 4 | តើអ្នកពេញចិត្តកម្រិតណា បើការធ្វើគម្រោងថវិកាកម្មវិធីត្រូវបានផ្សព្វផ្សាយទូលំទូលាយ? | 2.22 | 1.13 |
| 5 | តើអ្នកពេញចិត្តកម្រិតណា បើបុគ្គលិកអប់រំរបស់អង្គភាពថវិកាទទួលបានព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យស្មើៗគ្នា? | 2.33 | 1.10 |
| 6 | តើអ្នកពេញចិត្តកម្រិតណា បើអ្នកត្រូវបានផ្តល់ឱកាសក្នុងការអនុម័តគម្រោងថវិកាកម្មវិធី? | 2.47 | 1.01 |

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh (RUPP)

| | | | |
|---|---|---|---|
| 7 | តើអ្នកពេញចិត្តកម្រិតណា បើគម្រោងថវិកាកម្មវិធីប្រចាំឆ្នាំត្រូវបានអនុម័តត្រឹមគណៈគ្រប់គ្រង ? | 2.88 | 1.10 |
| 8 | តើអ្នកពេញចិត្តកម្រិតណា បើការអនុម័តថវិកាកម្មវិធីរបស់អង្គភាពថវិកាចំណាយពេលយូរហួសការរំពឹងទុក ? | 3.85 | 1.19 |
| 9 | តើអ្នកពេញចិត្តកម្រិតណា បើការអនុម័តថវិកាកម្មវិធីរបស់អង្គភាពថវិកានេះត្រូវបានធ្វើឡើងតាមឋានានុក្រម ? | 2.74 | 1.10 |
| សរុបជាមធ្យម | | 2.78 | 1.08 |

**<u>ចំណាំ៖</u>** ខ្នាតរង្វាស់ពី ១ ដល់ ៥ ( ១ = ពេញចិត្តទាំងស្រុង, ៥ = មិនពេញចិត្តទាំងស្រុង )

*M = គិតជាមធ្យម, SD = គម្លាតស្តង់ដា*